**THE COMMONWEALTH OF MASSACHUSETTS**
**THE TRIAL COURT**
**PROBATE AND FAMILY COURT ADMINISTRATIVE OFFICE**
**Three Center Plaza, Suite 210**
**Boston, MA 02108**

**John D. Casey**
**Chief Justice**

**TEL: (617) 788-6600**
**FAX: (617) 788-8995**

# វិសោធនកម្មបណ្តោះអាសន្ន
# ទៅលើអាណត្តិត័យចិន្ត្រៃយ៍ 2-16 – ការចូលរួមកម្មវិធីអប់រំមាតាបិតា

ដោយសារស្ថានការនៃកូវីដ-19, ចូលជាធរមានជាបន្ទាន់, និងរហូតដល់មានការជូនដំណឹងបន្ថែមទៀត, វិសោធនកម្មជាបណ្តោះអាសន្នទៅលើអាណត្តិភ័យចិន្ត្រៃយ៍ 2-16 នេះនឹងជំនួសវគ្គ H (1) នៃអាណត្តិភ័យចិន្ត្រៃយ៍ 2-20 របស់តុលាការមរតកនិងគ្រួសារ និងខដែលមានចែងមិនស្របគ្នាទាំងប៉ុន្មាននៃអាណត្តិភ័យចិន្ត្រៃយ៍របស់តុលាការមរតក និងគ្រួសារ 2-16 "ការចូលរួមកម្មវិធីអប់រំមាតាបិតា"៖

1. នៅពេលណាដែលអាចអនុវត្តបាន និងអាចធ្វើទៅបាន អ្នកផ្តល់ការអប់រំមាតាបិតាដែលត្រូវបានគេយល់ព្រមហើយអាចជួយសម្រួលដល់ការចូលរួម "ដោយប្រយោល" របស់មាតាបិតាក្នុងវគ្គអប់រំឳពុកម្តាយតាមរយៈការជួបតាមវីឌីអូ។ អ្នកផ្តល់ការអប់រំមាតាបិតាដែលត្រូវបានគេយល់ព្រម បើសិនជាជ្រើសរើសធ្វើ នឹងត្រូវបានគេផ្តល់ការយល់ព្រមជាបណ្តោះអាសន្នដើម្បីបង្រៀនមាតាបិតានូវវគ្គសិក្សាអប់រំតាមរយៈការជួបតាមវីឌីអូ ដោយប្រើប្រាស់ប្រព័ន្ធដូចជា Zoom និង Skype។

2. មាតាបិតាក៏អាចបំពេញតំរូវការការចូលរៀនរបស់ឳពុកម្តាយដោយបញ្ចប់កម្មវិធីឌីវីឌី(DVD) ឬអនឡាញរយៈពេល ៥ ម៉ោង ដែលមានចំណងជើងថា ឃីដឃែរ(*KidCare*)សំរាប់សហមាតាបិតា៖ *កម្មវិធីអប់រំសំរាប់គ្រួសារដែលលែងលះគ្នា*។

3. មាតាបិតាដែលជ្រើសបំពេញនូវតម្រូវការការអប់រំមាតាបិតាដែលចាំបាច់ដោយការចូលរួមតាមរយៈការជួបតាមវីឌីអូអនឡាញ ឬដោយ *KidCare សម្រាប់សហមាតាបិតា*៖ DVD *កម្មវិធីអប់រំសម្រាប់គ្រួសារដែលលែងលះគ្នា* ឬកម្មវិធីអនឡាញ មិនចាំបាច់ទទួលការអនុញ្ញាតពីតុលាការឡើយ។

4. ខដែលមានចែងផ្សេងទៀតទាំងអស់នៃអាណត្តិភ័យចិន្ត្រៃយ៍ 2-16 ដែលមិនប៉ះពាល់ដោយសេចក្តីជូនដំណឹងនេះនឹងនៅតែមានប្រសិទ្ធិភាពដដែល។

5. បញ្ជីកម្មវិធីដែលត្រូវបានអនុម័តនាពេលបច្ចុប្បន្នរួមមាន *KidCare សម្រាប់សហមាតាបិតា៖ កម្មវិធីអប់រំសម្រាប់គ្រួសារលែងលះគ្នា*មាននៅ៖https://www.mass.gov/info-details/parent-education-programs. មាតាបិតាគួរតែទាក់ទងកម្មវិធីដែលបានគេអនុញ្ញាតដោយផ្ទាល់ទាក់ទងការចុះឈ្មោះ និងកន្លែងទំនេរ។

ខែមីនា24, 2020
កាលបរិច្ឆេត

/s/ John D. Casey
ចៅក្រម John D. Casey
ប្រមុខចៅក្រម (Chief Justice)
តុលាការផ្នែកមរតក និងគ្រួសារ